សម្រាប់ការចេញផ្សាយបន្ទាន់ សេចក្តីប្រកាសព័ត៌មាន

# វិស័យធានារ៉ាប់រងសម្លឹងឃើញការរីកចម្រើនប្រកបដោយស្ថិរភាព ជាមួយនឹងការបង្ហាញខ្លួននៃការធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា

**ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា** - បុព្វលាភរ៉ាប់រងដុលសរុបក្នុងវិស័យធានារ៉ាប់រងនៅកម្ពុជាមានការកើនឡើងចំនួន ៣៨% នៅក្នុងត្រីមាសទីមួយឆ្នាំ ២០១៦ ធៀបនឹងត្រីមាសទីមួយឆ្នាំ ២០១៥ ដោយកើនពី ២១ លានដុល្លារអាមេរិក រហូតដល់ ២៩ លានដុល្លារអាមេរិក។ ការកើនឡើងនេះមានការរួមចំណែកពីការកើនឡើងនៃវិស័យធានារ៉ាប់រងទូទៅចំនួន ២០% និង វិស័យធានារ៉ាប់រងអាយុជីវិតដែលជាវិស័យថ្មីចំនួន ១២៣% ដោយគិតត្រឹមត្រីមាសទីមួយ ឆ្នាំ ២០១៦នេះ។

វិស័យធានារ៉ាប់រងទូទៅនៅកម្ពុជានៅតែបន្តការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ បច្ចុប្បន្ន ក្រុមហ៊ុនធានារ៉ាប់រងទូទៅសរុបចំនួន ៧ នៅកម្ពុជាបានរួមចំណែកក្នុងទំហំបុព្វលាភរ៉ាប់រងដុល ចំនួន ២០.៣ លានដុល្លារអាមេរិក នៅត្រីមាសទីមួយឆ្នាំ ២០១៦ នេះ។ បើប្រៀបធៀបទៅនឹងត្រីមាសទីមួយឆ្នាំមុន បុព្វលាភដុលក្នុងវិស័យធានារ៉ាប់រងទូទៅ កើនឡើងចំនួន ២០%។ កំណើននេះ មានការរួមចំណែកមួយផ្នែក ពី ធានារ៉ាប់រងសុខភាព ដែលកើន ៦៧% ពី ២,៤ លានដុល្លារអាមេរិក ដល់ ៤ លានដុល្លារអាមេរិក, ធានារ៉ាប់រងវិស្វកម្ម ដែលកើន ៤៩% ពី ០,៩ លានដុល្លារអាមេរិក ដល់ ១,៣ លានដុល្លារអាមេរិក, និង ធានារ៉ាប់រងនាវា យន្តហោះ និងដឹកជញ្ជូន ដែលកើន ៩៣% ពី ០,៦ លានដុល្លារអាមេរិក ដល់ ១,២ លានដុល្លារអាមេរិក។

**លោក ហ៊ុយ វ៉ាថារ៉ូ** ប្រធានសមាគមធានារ៉ាប់រងកម្ពុជា ជឿជាក់ថាវិស័យធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងទូទៅ កំពុងដំណើរការប្រកបដោយភាពវិជ្ជមាន។ លោកបានមានប្រសាសន៍ថា ៖ *«ខ្ញុំរីករាយជាខ្លាំងដោយឃើញ វិស័យធានារ៉ាប់រងទូទៅ និងវិស័យធានារ៉ាប់រងអាយុជីវិតនេះ ដើរទៅមុខគួរឱ្យកត់សម្គាល់។ លទ្ធផលនេះសរបញ្ជាក់ឱ្យឃើញពីទំនុកចិត្តកាន់តែខ្លាំងរបស់សាធារណជនទៅលើវិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។»*

*រាល់តួលេខដែលប្រើនៅក្នុងសេចក្តីប្រកាសព័ត៌មាននេះ គឺដើម្បីការធ្វើបទបង្ហាញតែប៉ុណ្ណោះ។*

វិស័យធានារ៉ាប់រងអាយុជីវិតគឺជាវិស័យមួយថ្មីនៅឡើយសម្រាប់កម្ពុជាដោយទើបតែចាប់កំណើតឡើងក្នុងឆ្នាំ ២០១២ ប៉ុណ្ណោះ បើទោះបីជាវិស័យនេះមានវត្តមាននៅក្នុងបណ្ដាប្រទេសជាច្រើនផ្សេងទៀតក្នុងតំបន់អាស៊ី ជាច្រើនទសវត្សមកហើយក៏ដោយ។ យោងតាមសមាគមធានារ៉ាប់រងកម្ពុជា ការយល់ដឹងអំពីវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា មានការកើនឡើងជាលំដាប់ចាប់តាំងពីពេលដែលវិស័យនេះមានវត្តមាន និងមានការរីកលូតលាស់រហូតដល់មានក្រុមហ៊ុន ធានារ៉ាប់រងអាយុជីវិតចំនួន ៤ ហើយនាពេលបច្ចុប្បន្ននៅកម្ពុជា ។ លោក Robert Elliott អនុប្រធាន សមាគមធានារ៉ាប់រងកម្ពុជា ទទួលបន្ទុកផ្នែកធានារ៉ាប់រងអាយុជីវិត បានលើកឡើងថាការវិវត្តទៅមុខនៃវិស័យធានារ៉ាប់រងអាយុជីវិតនេះ ទទួលបានការជ្រោមជ្រែងយ៉ាងខ្លាំងពីកិច្ចសហការរវាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសមាគមធានារ៉ាប់រងកម្ពុជា ក្នុងការបង្កើតឱ្យមានវគ្គសិក្ខាសាលាអប់រំដើម្បីឱ្យប្រជាជនយល់ដឹងកាន់តែខ្លាំងឡើងអំពីតួនាទីនៃការធានារ៉ាប់រងអាយុជីវិត។

ក្នុងឆ្នាំ ២០១៥ បុព្វលាភដុលក្នុងវិស័យធានារ៉ាប់រងមានការកើនឡើងចំនួន ១៩១% បើធៀបទៅនឹងបុព្វលាភដុលកាលពីឆ្នាំ ២០១៤ គឺកើនឡើងពីចំនួន ៧,៦ លានដុល្លារអាមេរិក ដល់ចំនួន ២២,១ លានដុល្លារអាមេរិក ជាមួយនឹងទឹកប្រាក់ធានាសរុបចំនួន ៦៥០ លានដុល្លារអាមេរិក។ វិស័យនេះនៅតែបន្តការរីកចម្រើនទៅមុខឥតឈប់ឈររហូតដល់ត្រីមាសទីមួយឆ្នាំ ២០១៦ គឺមានការកើនឡើងរហូតដល់ ១២៣% ដែលស្មើរនឹងទឹកប្រាក់ ៨,៩ លានដុល្លារអាមេរិក ដោយកើនឡើងពីចំនួនទឹកប្រាក់ ៤ លានដុល្លារអាមេរិក កាលត្រីមាសទីមួយឆ្នាំ ២០១៥។

សមាគមធានារ៉ាប់រងកម្ពុជា មានសុទិដ្ឋិនិយមជាខ្លាំងចំពោះដំណើរឈានទៅមុខនៃវិស័យធានារ៉ាប់រងនៅកម្ពុជា ដោយសារវិស័យនេះបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងអនាគតដ៏ប្រសើរសម្រាប់ក្រុមគ្រួសារកម្ពុជា និងការពន្លឿនការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលវែង។ លោក Robert Elliott មានប្រសាសន៍ទៀតថា៖ *«ខ្ញុំមានមោទនភាពជាខ្លាំងចំពោះវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជាដែលវិស័យនេះបានការពារប្រជាជនចំនួន ៣៥,០០០ នាក់ហើយ ជាមួយនឹងទឹកប្រាក់ធានាសរុបចំនួនប្រមាណ ៨០០ លានដុល្លារអាមេរិក គិតត្រឹមចុងត្រីមាសទីមួយ ឆ្នាំ ២០១៦។»*

ទន្ទឹមនឹងនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវជោគជ័យដ៏ធំធេងនេះ។ លោក Robert Elliott បានបន្ថែមថា៖ *«ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការផ្ដល់នូវទំនុកចិត្ត ការសហការ គាំទ្រលើវិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា។ ប្រសិនបើគ្មានកិច្ចសហការដ៏ល្អនេះទេ វិស័យនេះពិតជាមិនអាចរីកលូតលាស់ទៅយ៉ាងលឿនបែបនេះឡើយ។ ជាមួយនឹងកិច្ចបន្តគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំមាន*

*រាល់តួលេខដែលប្រើនៅក្នុងសេចក្ដីប្រកាសព័ត៌មាននេះ គឺដើម្បីការធ្វើបទបង្ហាញតែប៉ុណ្ណោះ។*

*ជំនឿជាក់យ៉ាងមុតមាំថា  វិស័យនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងអនាគតហិរញ្ញវត្ថុមួយដ៏ប្រសើរសម្រាប់គ្រប់ក្រុមគ្រួសារកម្ពុជា។»*

អាសយដ្ឋានទំនាក់ទំនងសម្រាប់សារព័ត៌មាន

លោក ហ៊ុយ វ៉ាថារ៉ូ
ប្រធាន
សមាគមធានារ៉ាប់រងកម្ពុជា
ទូរស័ព្ទលើតុ៖ (៨៥៥) ២៣ ៨៨០ ២២២
ទូរស័ព្ទដៃ៖ (៨៥៥) ១២ ៦៩៤ ៥៩៥
អ៊ីមែល៖ vatharo_huy@iac.org.kh

លោក Robert Elliott
អនុប្រធានទទួលបន្ទុកផ្នែកធានារ៉ាប់រងអាយុជីវិត
សមាគមធានារ៉ាប់រងកម្ពុជា
ទូរស័ព្ទលើតុ៖ (៨៥៥) ២៣ ៩៦៥ ៩៦៥
ទូរស័ព្ទដៃ៖ (៨៥៥) ៨៧ ២២២ ២០៧
អ៊ីមែល៖ Robert_Elliott@manulife.com

*រាល់តួលេខដែលប្រើនៅក្នុងសេចក្តីប្រកាសព័ត៌មាននេះ គឺដើម្បីការធ្វើបទបង្ហាញតែប៉ុណ្ណោះ។*